ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

# សាររំលែកមរណទុក្ខ
# ជូនចំពោះ
# លោកជំទាវ លាង ខួចឆេង ហ៊ុនណេង និងក្រុមគ្រួសារនៃ
# សពឯកឧត្តមព្រឹទ្ធាចារ្យ ហ៊ុន ណេង

**លោកជំទាវ ជាទីរាប់អានយ៉ាងជ្រាលជ្រៅ!**

ខ្ញុំ និងភរិយា ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកគ្រប់ជាន់ថ្នាក់នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ព្រមទាំងមន្ត្រីការទូតកម្ពុជាទាំងអស់ដែលកំពុងបំពេញបេសកកម្មការទូតនៅបរទេសមានសេចក្តីរន្ធត់ចិត្ត និងសោកស្តាយយ៉ាងក្រៃលែង បន្ទាប់ពីបានទទួលដំណឹងដ៏សែនក្រៀមក្រំអំពីមរណភាពរបស់ **ឯកឧត្តមព្រឹទ្ធាចារ្យ ហ៊ុន ណេង សមាជិកអចិន្ត្រៃយ៍រដ្ឋសភា អ្នកតំណាងរាស្ត្រមណ្ឌលខេត្តកំពង់ចាម និងជាប្រធានគណៈកម្មការទី៤នៃរដ្ឋសភា** នាថ្ងៃព្រហស្បតិ៍ ៥កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២២ ក្នុងជន្មាយុ ៧២ឆ្នាំ ដោយពេគាពាធ។

មរណភាពរបស់ **ឯកឧត្តមព្រឹទ្ធាចារ្យ ហ៊ុន ណេង** គឺជាការបាត់បង់ឥស្សរជននយោបាយដ៏ឆ្នើមមួយរូបរបស់ព្រះរាជាណាចក្រកម្ពុជា ដែលកន្លងមក **ឯកឧត្តមព្រឹទ្ធាចារ្យ** បានលះបង់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី និងធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិមាតុភូមិ និងការបាត់បង់ ស្វាមី ឪពុក និងជីតា ប្រកបដោយព្រហ្មវិហារធម៌ គួរជាទីគោរព និងស្រឡាញ់ស្មើជីវិតចំពោះកូនចៅគ្រប់ពេលវេលា។

ក្នុងឱកាសដ៏សែនក្រៀមក្រមនេះ ខ្ញុំ និងភរិយា ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកគ្រប់ជាន់ថ្នាក់នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមចូលរួមរំលែកមរណទុក្ខ សោកស្តាយ អាឡោះអាល័យជាទីបំផុតជាមួយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា ឯកឧត្តម លោកជំទាវ និងក្រុមគ្រួសារ** ដោយក្តីសង្វេគឥតឧបមា និងសូមឧទ្ទិសបួងសួងសុំឱយដួងវិញ្ញាណក្ខ័ន្ធរបស់ **ឯកឧត្តមព្រឹទ្ធាចារ្យ ហ៊ុន ណេង** បានសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម លោកជំទាវ និងក្រុមគ្រួសារ ទទួលនូវការរំលែកទុក្ខដ៏សែនក្រៀមក្រំនេះពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃ សុក្រ ៦កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០២២

**ប្រាក់ សុខុន** **ខេង សំវ៉ាដា**

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh